# វគ្គបណ្តុះបណ្តាលខ្លីសំរាប់និស្សិត

- តើប្អូនៗនិស្សិតមានការលំបាកក្នុងការសរសេរនិក្ខេបបទ ឬរបាយការណ៍បញ្ចប់ការសិក្សារបស់ខ្លួនមែនទេ?
- តើប្អូនៗនិស្សិតចង់បានចំណេះដឹង និងជំនាញពិតប្រាកដក្នុងការស្រាវជ្រាវដើម្បីសរសេរនិក្ខេបបទ ឬរបាយការណ៍ បញ្ចប់ការសិក្សារបស់ខ្លួនប្រកបដោយគុណភាពមែនទេ?
- តើប្អូនៗនិស្សិតចង់បានបទពិសោធន៍ជាក់ស្តែងក្នុងការងារស្រាវជ្រាវ សរសេររបាយការណ៍ រៀបចំ និងឡើងធ្វើបទបង្ហាញមែនទេ?

យើងអាចជួយប្អូនៗដើម្បីដោះស្រាយកង្វល់ខាងលើ ព្រមទាំងបំពេញតំរូវការរបស់ប្អូនៗក្នុងការស្វែងរកចំណេះដឹង ជំនាញ និងបទពិសោធន៍ជាក់ស្តែងបាន។ **វិទ្យាស្ថាន សេដាកដើម្បីអភិវឌ្ឍន៍មូលដ្ឋាន** ដែលជាស្ថាប័នបណ្តុះបណ្តាលធនធានមនុស្សរបស់ **អង្គការ សេដាក** នឹងបើកវគ្គបណ្តុះបណ្តាលសំរាប់ប្អូនៗនិស្សិត ក៏ដូចជាអ្នកមានចំណាប់អារម្មណ៍ផ្សេងទៀត លើប្រធានបទ **"វិធីសាស្ត្រស្រាវជ្រាវសង្គម" ឬ " Social Research Method"** ដែលមានរយៈពេល ៤ ថ្ងៃ ។ ការបណ្តុះបណ្តាលនេះចែកជា ២ វគ្គ រៀននៅថ្ងៃសៅរ៍-អាទិត្យ:

- វគ្គទី ១ នៅថ្ងៃទី ២៨ កុម្ភៈ-០១ មីនាៈ គឺរៀនទ្រឹស្តី និងធ្វើលំហាត់សាកល្បង បន្ទាប់មកសិក្ខាកាមចុះអនុវត្តការប្រមូលទិន្នន័យ
- វគ្គទី ២ នៅថ្ងៃទី ២១-២២ មីនាៈ គឺរៀនវិភាគទិន្នន័យ និងសរសេររបាយការណ៍ ព្រមទាំងការធ្វើបទបង្ហាញ។

**ក្រោយពីបញ្ចប់វគ្គបណ្តុះបណ្តាល សិក្ខាកាមនឹងទទួលបានៈ**

- *ចំណេះដឹង និងជំនាញក្នុងការៈ*
    - បង្កើតគំរោងសំណើរសរសេរនិក្ខេបបទបញ្ចប់ការសិក្សា
    - បង្កើតគំរោងស្រាវជ្រាវ និងបញ្ជីរសំណួរសំរាប់ប្រមូលទិន្នន័យ
    - ប្រមូលទិន្នន័យ
    - វិភាគទិន្នន័យ និងសរសេររបាយការណ៍
    - រៀបចំ និងធ្វើបទបង្ហាញ
- *វិញ្ញាបនបត្របញ្ជាក់ការសិក្សា*

- បង្រៀនដោយសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ និងបុគ្គលិកអង្គការ សេដាក ដែលមានបទពិសោធន៍យូរឆ្នាំ។

- ចាប់ផ្តើមចុះឈ្មោះពីថ្ងៃផ្សាយដំណឹងនេះតទៅនៅអាសយដ្ឋាន ផ្ទះសង់ថ្មី ភូមិភ្នំពេញថ្មី ផ្លូវ ១០០៣ សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទូរស័ព្ទ: ៨៥៥-២៣ ៨៨០ ០៦៥/ ០១៧ ៩០៧ ២០១
- តំលៃសិក្សា **២០ ដុល្លារ/នាក់** ហើយ**បញ្ចុះតំលៃ ១០%** សំរាប់ការចុះឈ្មោះ ១០ នាក់ដំបូង ។